ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបិទវគ្គគ្រូលែនកម្រិតមូលដ្ឋានទី១ និងបើកវគ្គគ្រូលែនកម្រិតមូលដ្ឋានទី២ ស្តីពីភាពជាអ្នកដឹកនាំ
**នៅធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤**

សូមគោរព ៖

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដោយបានចូលរួមក្នុងពិធីបិទវគ្គបណ្តុះបណ្តាលកម្រិតមូលដ្ឋាន ស្តីពី "ភាពជាអ្នកដឹកនាំ" នាពេលនេះ ។ ដោយមានសំណូមពរពីគណៈកម្មាធិការរៀបចំវគ្គ ខ្ញុំសូមប្រសិទ្ធនាមវគ្គបណ្តុះបណ្តាលនេះថា "វគ្គគ្រូលែនកម្រិតមូលដ្ឋានទី១ ស្តីពីភាពជាអ្នកដឹកនាំ" សម្រាប់ពង្រឹងសមត្ថភាពជាអ្នកដឹកនាំដល់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាយើង ។ នៅឆ្នាំនេះ យើងរៀបចំពិធីបិទវគ្គគ្រូលែនកម្រិតមូលដ្ឋានទី១ ដំណាលគ្នាក្នុងថ្ងៃតែមួយជាមួយនឹងពិធីបើកវគ្គគ្រូលែនកម្រិតមូលដ្ឋានទី២ ស្តីពីភាពជាអ្នកដឹកនាំផងដែរ ។ ការរៀបចំបែបនេះ គឺដើម្បីបង្កបរិយាកាសឱ្យមន្ត្រីសិក្ខាកាមវគ្គទី១និងវគ្គទី២បានជួបប្រាស្រ័យគ្នា ផ្លាស់ប្តូរយោបល់គ្នា ចែករំលែកបទពិសោធន៍គ្នា និងដើម្បីពង្រឹងបណ្តាញការងារ (networking) ឱ្យកាន់តែល្អប្រសើរនិងមានប្រសិទ្ធភាពថែមទៀត ។

តាមរយៈរបាយការណ៍របស់ លោក ថៃ សភា ខ្ញុំសូមវាយតម្លៃយ៉ាងខ្ពស់ថា វគ្គគ្រូលែនកម្រិតមូលដ្ឋានទី១ ស្តីពីភាពជាអ្នកដឹកនាំ រយៈពេល ៣ខែនេះ បានប្រព្រឹត្តទៅយ៉ាងសកម្មនិងប្រកបដោយជោគជ័យ ហើយបានផ្តល់ចំណេះដឹងទាក់ទងនឹងទស្សនាទានជាមូលដ្ឋានស្តីពីភាពជាអ្នកដឹកនាំ យល់ដឹងពីទស្សនវិស័យនិងមុខងារ-ភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជាក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ វិធីសាស្ត្រនិងរបៀបប្រាស្រ័យទាក់ទងជាមួយថ្នាក់ដឹកនាំ ឥរិយាបថនិងប្រសិទ្ធភាពនៃការងារបុគ្គលនិងក្រុមជាដើម ។ ខ្ញុំសូមចូលរួមអបអរសាទរចំពោះលទ្ធផលដែលក្មួយៗទាំងអស់បានខិតខំប្រឹងប្រែងសម្រេចបានប្រកប



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដោយជោគជ័យនាពេលនេះ ។ ចំណេះដឹងទាំងនេះ គឺជាប្រភពទុននិងជាយានមួយយ៉ាងសំខាន់សម្រាប់បំពេញការងារនិងជីវភាពប្រចាំថ្ងៃរបស់ក្មួយៗ ។

ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោក Faisal Ahmed តំណាងអង្គការមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា លោក Arnaud de Villepoix ជំនាញការទូទៅរបស់ IMF ប្រចាំធនាគារជាតិនៃកម្ពុជា លោកជំទាវទេសាភិបាលរង ថ្នាក់ដឹកនាំ និងមន្ត្រីឧទ្ទេសនាមរបស់យើងទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកចែករំលែកចំណេះដឹងនិងបទពិសោធន៍ល្អៗជូនដល់មន្ត្រីធនាគារជាតិនៃកម្ពុជាយើង ។

**- គណៈអធិបតី**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រីឧទ្ទេសនាម និងក្មួយៗសិក្ខាកាម ជាទីមេត្រី!**

ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ជម្រាបពីមូលហេតុដែលខ្ញុំជ្រើសរើសយកពាក្យ "គូលែន" មកប្រសិទ្ធនាមឱ្យឈ្មោះវគ្គបណ្តុះបណ្តាលនេះបន្តិច ។ ពាក្យ "គូលែន" ខ្ញុំមិនសំដៅដល់ឈ្មោះផ្លែឈើនោះទេ ប៉ុន្តែខ្ញុំចង់រំលឹកពីទីតាំងប្រវត្តិសាស្ត្រនិងវីរភាពរបស់ព្រះមហាក្សត្រខ្មែរដែលមានភាពជាអ្នកដឹកនាំដ៏ប៉ិនប្រសប់នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើងកន្លងមក គឺ៖

១/- ឈ្មោះភ្នំគូលែន ស្ថិតក្នុងខេត្តសៀមរាប ទឹកដីប្រវត្តិសាស្ត្រកម្ពុជាយើង ។ ភ្នំគូលែននេះ មានឈ្មោះដើមថា *មហេន្ទ្រពិត* ដែលជាកន្លែងដែលអតីតព្រះមហាវីរក្សត្រខ្មែរព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) បានជ្រើសរើសយកជាទីតាំងសម្រាប់ប្រារព្ធពិធីទេវរាជ និងដឹកនាំចលនាស្នេហាជាតិ ដើម្បីបង្រួបបង្រួមទឹកដីនិងដណ្តើមឯកភាពជាតិឡើងវិញ បន្ទាប់ពីប្រទេសកម្ពុជាបានចុះទន់ខ្សោយនិងបែកចេញជាពីរ គឺ*អាណាចក្រចេនឡាដីគោក និងចេនឡាដីទឹក* ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជ្វាក្នុងចុងសតវត្សរ៍ទី៨ ។

២/- ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញពីទីតាំងដែលជានិមិត្តរូបនៃការខិតខំប្រឹងប្រែងកសាងកម្លាំង ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប៉ិនប្រសប់របស់ព្រះបាទជ័យវរ្ម័នទី២ ដែលបានបង្រួបបង្រួមទឹកដីដែលបែកបាក់ មកឯកភាពជាតិតែមួយ និងជាចំណុចចាប់ផ្តើមនៃសម័យអង្គរដ៏រុងរឿងនៃប្រវត្តិសាស្ត្រកម្ពុជាយើង *និង*

៣/- បង្ហាញពីភាពម្ចាស់ការរបស់ថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងខិតខំរៀបចំបណ្តុះបណ្តាលនិងអភិវឌ្ឍធនធានមនុស្សដែលជាកម្លាំងបន្តវេនដោយខ្លួនឯង ដើម្បីរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជាឱ្យកាន់តែរីកចម្រើន និងមានលក្ខណៈសមាហរណជាមួយប្រទេសក្នុងតំបន់និងពិភពលោកថែមទៀត ។

តើក្មួយៗដឹងទេ ប្រទេសជាតិមួយមានការឯកភាពជាតិនិងការអភិវឌ្ឍរីកចម្រើនរុងរឿង គឺកើតឡើងដោយសារការដឹកនាំដ៏ប៉ិនប្រសប់និងឈ្លាសវាងវៃរបស់ថ្នាក់ដឹកនាំនៃប្រទេសនោះ ។ ជាក់ស្តែង បើតាមព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើងថ្មីៗនេះ ក្មួយៗបានដឹងនិងបានឃើញហើយ នៅឆ្នាំ១៩៩៨ អនុវត្តតាមនយោបាយឈ្នះឈ្នះរបស់រាជរដ្ឋាភិបាល សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំប្រទេសកម្ពុជាឱ្យមានសន្តិភាពនៅទូទាំងប្រទេស ១០០ភាគរយ និងមានការអភិវឌ្ឍលើគ្រប់វិស័យ ហើយមានលក្ខណៈសមាហរណជាមួយប្រទេសក្នុងតំបន់និងពិភពលោក ។ នេះគឺជាមេរៀន Leadership មួយយ៉ាងសំខាន់ផងដែរ ដែលបង្ហាញឱ្យប្រជាជនកម្ពុជាយល់ច្បាស់ពីវីរភាពអង់អាចក្លាហានរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី និងវីរជនស្នេហាជាតិជាច្រើនរូបទៀត ដែលបានរំដោះប្រទេសនិងសង្គ្រោះប្រជាជនកម្ពុជាឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ ហើយបានដឹកនាំប្រទេសឆ្ពោះទៅរកសន្តិភាពនិងការអភិវឌ្ឍលើគ្រប់វិស័យរហូតដល់សព្វថ្ងៃនេះ ។ បទពិសោធន៍និងមេរៀននៃប្រវត្តិសាស្ត្របានបង្រៀនយើងយ៉ាងច្រើនលើគ្រប់ទិដ្ឋភាព ក្នុងនោះក៏មានភាពជាអ្នកដឹកនាំច្រើនណាស់ដែរ នៅតាមដំណាក់កាលប្រវត្តិសាស្ត្រនីមួយៗ ។ ពេលវេលានិងព្រឹត្តិការណ៍ជាអ្នកបង្កើតវីរបុរសនិងប្រវត្តិសាស្ត្រ ។ តាមរយៈព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនិងវីរជននោះ អាចឆ្លុះបញ្ចាំងឱ្យយើងឃើញពីភាពជាអ្នកដឹកនាំបាន ។ ដំណាក់កាលខ្លះនាំមកនូវភាពរុងរឿង និងដំណាក់កាលខ្លះនាំឱ្យប្រទេសជាតិវិនាសអន្តរាយ ឧទាហរណ៍ជាក់ស្តែង គឺដំណាក់កាលនៃរបបប្រល័យពូជសាសន៍ប៉ុលពត ។ សូមក្មួយៗទាំងអស់ចងចាំទុកនិងរួមចំណែកការពារសមិទ្ធផលសង្គមជាតិដែលយើងបានខិតខំកសាងឡើង និងជៀសវាងកុំឱ្យប្រវត្តិសាស្ត្រជាន់ដានចាស់ ដូចពាក្យមួយថា "Don't let our history repeats itself" ។

ការកសាងធនធានមនុស្ស គឺជាគន្លឹះយ៉ាងសំខាន់សម្រាប់ធានានិរន្តរភាពស្ថាប័ន និងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនឈានឡើង ។ ការអភិវឌ្ឍធនធានមនុស្សចាំបាច់ត្រូវធ្វើជាប់ជាប្រចាំ ដូចភ្លៀងរលឹម សម្រាប់ធានានូវនិរន្តភាពការងាររបស់យើង ។ កន្លងមក យើងបាននិងកំពុងបណ្តុះបណ្តាលមន្ត្រីបុគ្គលិកយើងលើជំនាញឯកទេសកម្មខាងត្រួតពិនិត្យ បញ្ញត្តិកម្ម សវនកម្ម គណនេយ្យ ការរៀបចំគោលនយោបាយរូបិយវត្ថុ ការវិភាគសេដ្ឋកិច្ច និងការគ្រប់គ្រងទុនបម្រុងអន្តរជាតិជាដើម ក្រោមរូបភាពជា In-house trainings និងនៅក្រៅប្រទេស ដូចជា ការចូលរួមសិក្ខាសាលានិងកិច្ចប្រជុំនានាជាដើម ។ ការផ្តួចផ្តើមគំនិតរៀបចំវគ្គគូលែនកម្រិតមូលដ្ឋានស្តីពីភាពជាអ្នកដឹកនាំនេះឡើង ស្របពេលជាមួយនឹងនិន្នាការរបស់ធនាគារកណ្តាលនៃប្រទេសក្នុងតំបន់ កំពុងយកចិត្តទុកដាក់បណ្តុះបណ្តាលមន្ត្រីរបស់ខ្លួនដែរ ក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលមន្ត្រីបុគ្គលិកឱ្យក្លាយជា